រាជបណ្ឌិត្យសភាកម្ពុជា

៣៤៣

# អវិជ្ជមានន័យក្នុងភាសាខ្មែរ តាមរយៈ អវិជ្ជមានបទនិងអវិជ្ជមានសព្ទមួយចំនួន (មិន ឥត កុំ គ្មាន អត់ ពុំ ..., ខុស អាក្រក់ ចាំតើ នាងល្អ...)

# Negative Meanings in the Khmer Language through Specific Negative words and Negative Expressions

( [mɯn], [ʔet], [kom], [khmęa:n], [ʔɑt], [pum],...;
[khoh], [ʔa: krɑk], [cam taə], [nęa:ŋ lʔɑ:]... )

ជួរ សារី

និក្ខេបបទបណ្ឌិតភាសាវិទ្យា

ឯកទេស ៖ ន័យវិទ្យា

២០១១

រាជបណ្ឌិត្យសភាកម្ពុជា

# អវិជ្ជមានន័យក្នុងភាសាខ្មែរ តាមរយៈ អវិជ្ជមានបទនិងអវិជ្ជមានសព្ទមួយចំនួន (មិន ឥត កុំ គ្មាន អត់ ពុំ ..., ខុស អាក្រក់ ចាំតើ នាងល្អ...)

# Negative Meanings in the Khmer Language through Specific Negative words and Negative Expressions

( [mɯn], [ʔet], [kom], [khmęa:n], [ʔɑ̣t], [pum],...;
[khoh], [ʔa: krɑ̣k], [cam taə], [nęa:ŋ lʔɑ̣:]... )

ជូរ គារី

និក្ខេបបទបណ្ឌិតភាសាវិទ្យា
ឯកទេស ៖ ន័យវិទ្យា

សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិត ច័ន្ទ សំណព្វ
សាស្ត្រាចារ្យណែនាំរង ៖ បណ្ឌិត ធ សោ

២០១១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**រាជបណ្ឌិត្យសភាកម្ពុជា**

Royal Academy of Cambodia
Académie Royale du Cambodge

លេខ៥៩៩/១១បសក

## សេចក្ដីសម្រេច
## ស្ដីពីការអនុញ្ញាតឱ្យបេក្ខជនបណ្ឌិតការពារបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិត

### ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស /រកត/០៣០៥/១១១ ចុះថ្ងៃទី៤ ខែមិនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលបទបញ្ញត្តិមួយចំនួន នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩

-យោងអនុក្រឹត្យលេខ ៨៤ អនក្រ/បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិត្យសភាកម្ពុជា

-យោងចំណារឯកភាពរបស់សម្ដេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ លើលិខិតស្នើសុំរបស់រាជបណ្ឌិត្យសភាកម្ពុជា អំពីគម្រោងបណ្ដុះបណ្ដាលនិស្សិតថ្នាក់បណ្ឌិតវគ្គទី១

-យោងគោលការណ៍ស្ដីពីល័ក្ខខ័ណ្ឌជ្រើសរើសនិងបណ្ដុះបណ្ដាលថ្នាក់បណ្ឌិតនៅរាជបណ្ឌិត្យសភាកម្ពុជា ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៨

-យោងចំណាររបស់សាស្ត្រាចារ្យណែនាំចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ស្ដីពីការអនុញ្ញាតឱ្យការពារបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិត

### សម្រេច

ប្រការ១ ៖ អនុញ្ញាតឱ្យលោក **ជួរ គារី** បេក្ខជនបណ្ឌិតវគ្គ១ មុខវិជ្ជា៖ **ភាសាវិទ្យា** នៃរាជបណ្ឌិត្យសភាកម្ពុជា ការពារបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិតនៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១១។

ប្រការ២ ៖ គណៈកម្មការវាយតម្លៃនិក្ខេបបទថ្នាក់បណ្ឌិត ផ្នែកបណ្ដុះបណ្ដាលនៃរាជបណ្ឌិត្យសភាកម្ពុជានិង សាមីខ្លួនត្រូវអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ២០១១

**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

**បណ្ឌិតសភាចារ្យ ខួត ធីដា**

អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ - ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា
Fax: (855) 23 890 180 Website: www.rac-academy.edu.kh, E-mail: arc_racademy@yahoo.com P.O Box 531 Phnom Penh, Cambodia

# មាតិកា

**ទំព័រ**

ឧទ្ទិសស្នាដៃ.......................................................................... iv
សេចក្ដីថ្លែងអំណរគុណ.......................................................................... v
អំណះអំណាង.......................................................................... vi
មូលន័យសង្ខេប (ភាសាខ្មែរ).......................................................................... xii
មូលន័យសង្ខេប( Abstract ).......................................................................... xiii
សង្ខេបនិក្ខេបបទ(ភាសាខ្មែរ).......................................................................... ix
សង្ខេបនិក្ខេបបទ( SUMMARY ).......................................................................... xiv
អារម្ភកថា .......................................................................... xviii

## សេចក្ដីផ្ដើម

១-លំនាំបញ្ហានៃការស្រាវជ្រាវ .......................................................................... ១
២-ចំណោទបញ្ហានៃការស្រាវជ្រាវ.......................................................................... ១
៣-គោលបំណងនៃការស្រាវជ្រាវ .......................................................................... ២
៤-ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ .......................................................................... ៣
៥-វិធីសាស្ត្រនៃការស្រាវជ្រាវ .......................................................................... ៣
៦-សារៈសំខាន់នៃការស្រាវជ្រាវ .......................................................................... ៣
៧-រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .......................................................................... ៣

## ជំពូកទី១
## អវិជ្ជមានន័យតាមរយៈអន្តរកម្មនិយមដែលជាមូលដ្ឋានគ្រឹះនៃការសិក្សាស្រាវជ្រាវប្រធានបទនិក្ខេបបទ

១- ជុំវិញបញ្ហានៃអវិជ្ជមានន័យ.......................................................................... ៧
២- ការកំណត់និយមន័យនៃបច្ចេកសព្ទមួយចំនួនដែលត្រូវសិក្សាក្នុងនិក្ខេបបទនេះ.......................... ៧
២.១-អវិជ្ជមានន័យ.......................................................................... ៨
២.២-អវិជ្ជមានបទ .......................................................................... ៨
២.៣-អវិជ្ជមានសព្ទ.......................................................................... ១០
២.៤-អវិជ្ជមានកម្ម.......................................................................... ១១
២.៥-អវិជ្ជមានភាព.......................................................................... ១២
២.៦- វិជ្ជមានភាព.......................................................................... ១៣
២.៧- គោលអវិជ្ជមាន.......................................................................... ១៤
២.៨- គោលវិជ្ជមាន.......................................................................... ១៤
២.៩- ទម្រង់វិជ្ជមាន.......................................................................... ១៥

២.១០- ទម្រង់អវិជ្ជមាន ........................................ ១៥

## ជំពូកទី២

## ទីតាំង លក្ខណៈសម្ព័ន្ធ និងតួនាទីរបស់អវិជ្ជមានបទ

១-អំពីអវិជ្ជមានបទ *មិន* ........................................ ១៨
១.១-សិក្សាពីសំណុំពាក្យដែលមានរចនាសម្ព័ន្ធទូទៅមានទម្រង់ *មិន+កិ.* ........................................ ១៩
១.២- សិក្សាពីសំណុំពាក្យ ដែលមានរចនាសម្ព័ន្ធទូទៅមានទម្រង់ *មិន+កិ.១+កិ.២* ........................................ ២០
១.៣- សិក្សាពីសំណុំពាក្យ ដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ កិ.+មិន+ឈ្នាក់ ........................................ ២២
១.៣.១-ឈ្នាក់ជាកិរិយាសព្ទ ........................................ ២២
១.៣.២- ឈ្នាក់ជាធាតុមួយដែលជាគុណកិរិយា/កិរិយាវិសេសន៍ ហើយវេយ្យាករណ៍ប្រពៃណី ហៅថា គុណនាម ........................................ ២៦
១.៣.៣- ឈ្នាក់បញ្ជាក់ពីបំណែប ........................................ ២៩
១.៣.៤- ឈ្នាក់បញ្ជាក់ពីទិដ្ឋភាព ........................................ ២៩
១.៤- ការសិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ មិន+ឈ្នាក់+កិ ........................................ ៣១
១.៥- សិក្សាពីមិន ដែលជាធាតុមួយនៃសន្ធានសព្ទ ........................................ ៣៥
១.៥.១-សិក្សាពីមិន ដែលជាធាតុនៃសន្ធានសព្ទ មិនយូរប៉ុន្មាន ........................................ ៣៧
១.៥.២- សិក្សាពីមិន ដែលជាធាតុនៃសន្ធានសព្ទ មិនតែប៉ុណ្ណោះ និង មិនតែប៉ុណ្ណោះសោត ........ ៣៨
២-អំពីអវិជ្ជមានបទ *ឥត* នៅក្នុងល្បះ ........................................ ៤៣
២.១- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ ឥត+គុ.កិ.+កិ.+ន ........................................ ៤៥
២.២-សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ កិ.+ឥត+ឈ្នាក់ ........................................ ៤៧
២.២.១- កិ.+ឥត+ឈ្នាក់បំណែប ........................................ ៤៨
២.២.២- កិ.+ឥត+ឈ្នាក់កាល ........................................ ៤៨
២.៣- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ ឥត+កិ. ........................................ ៥០
២.៤- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ ឥត+គុ.កិ ........................................ ៥១
៣-អំពីអវិជ្ជមានបទ *កុំ* នៅក្នុងល្បះ ........................................ ៥២
៣.១-សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ កុំ+ន. ........................................ ៥២
៣.២-សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ កុំ+កិ ........................................ ៥៣
៣.៣- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ កុំ+គុ ........................................ ៥៥
៣.៤- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ កុំ+និ ........................................ ៥៦
៤- អំពីអវិជ្ជមានបទគ្មាននៅក្នុងវាទរូប ........................................ ៥៦
៤.១- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ គ្មាន+ន ........................................ ៥៦
៤.២- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ គ្មាន+កិ ........................................ ៦០
៤.៣- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ គ្មាន+*Ø* ........................................ ៦១
៥- អំពីអវិជ្ជមានបទ អត់ នៅក្នុងល្បះ ........................................ ៦៥
៥.១- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ អត់+ន ........................................ ៦៥

៥.២- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ អត់+កិ........................................ ៦៨
៥.៣- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ អត់+គុ ........................................៦៨
៥.៤- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ អត់+ គុ.កិ........................................៧០
៥.៥- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ អត់+និ........................................ ៧១
៥.៦-សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ អត់+Ø........................................ ៧៣
៦- អំពីអវិជ្ជមានបទ *ពុំ* នៅក្នុងល្បះ ........................................៧៤
៦.១- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ ពុំ+កិ........................................ ៧៤
៦.២-សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ ពុំ+និ........................................ ៧៧
៦.៣-សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ ពុំ+គុ........................................៧៨
៦.៤- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ ពុំ+គុ.កិ........................................ ៨០
៦.៥- សិក្សាពី *ពុំ* ដែលជាធាតុមួយនៃសន្ទានសព្ទ........................................ ៨១
៦.៥.១- សិក្សាពី *ពុំ* ដែលជាធាតុមួយនៃសន្ទានសព្ទ ពុំនោះសោត ពុំនោះសោតទេ........................................៨១
៦.៥.២-សិក្សាពី *ពុំ* ដែលជាធាតុមួយនៃសន្ទានសព្ទ ពុំនោះទេ........................................ ៨៣

## ជំពូកទី៣

## ទីតាំង លក្ខណៈសម្ព័ន្ធ និងតួនាទីរបស់អវិជ្ជមានសព្ទ

១- សិក្សាពីសំណុំពាក្យដែលមានអវិជ្ជមានសព្ទ ខុស អាក្រក់ ........................................៨៥
១.១- សិក្សាពីសំណុំពាក្យអប្បរមាដែលមានទម្រង់ ខុស+ន. និង ន.+ខុស ........................................៨៦
១.២- សិក្សាពីសំណុំពាក្យអប្បរមាដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ កិ.+ខុស និង ខុស+កិ.........៩០
១.៣- សិក្សាពីសំណុំពាក្យអប្បរមាដែលមានទម្រង់ ខុស+សព្វ និង សព្វ+ខុស........................................ ៩១
១.៤- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ អាក្រក់+កិ. ........................................៩៤
១.៥- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ អាក្រក់+ន. និង ន.+អាក្រក់............ ៩៥
១.៦- សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ អាក្រក់+សព្វ. និង សព្វ.+អាក្រក់..... ៩៦
១.៧-សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ អាក្រក់+គុ. និង គុ.+អាក្រក់............៩៧
២-សិក្សាពីសំណុំពាក្យដែលអាចជាអវិជ្ជមានសព្ទដូចជា ចាំតើ ស្អែក( ឱ្យ...)នាងល្អ..................៩៨
២.១- សិក្សាពីសំណុំពាក្យចាំតើ........................................ ៩៨
២.២- សិក្សាពីសំណុំពាក្យ ស្អែកឱ្យ ........................................១០០
២.៣- សិក្សាពីសំណុំពាក្យ នាងល្អ ........................................ ១០១
៣-សិក្សាពីសំណុំពាក្យដែលអាចជាអវិជ្ជមានសព្ទគោបាត់ទើបធ្វើរបងពេលប្រឡងទើបខំរៀន... ១០២
សន្និដ្ឋាន........................................១០៣
**គន្ថនិទ្ទេស**........................................១០៦
**ឧបសម្ព័ន្ធ** ........................................I
**ពន្យល់ពាក្យ**........................................xx

# មូលន័យសង្ខេប

ប្រធានបទស្ដីអំពីអវិជ្ជមានន័យនេះ យើងខ្ញុំយកទ្រឹស្ដីអន្តរកម្មនិយមមកធ្វើជាមូលដ្ឋាននៃការវិភាគដែលមានលក្ខណៈបែបអាតូមិក ពោលគឺជាការសិក្សាទៅលើឯកតាភាសាម្ដងមួយៗ ដែលមើលទៅហាក់បីដូចជាការសិក្សាដ៏តូចមួយ ប៉ុន្តែ តាមការពិតវាមានវិសាលភាពទូលំទូលាយ ដោយការសិក្សាបែបនេះមានជាប់ទាក់ទងទៅនឹងទិដ្ឋភាពជាច្រើនដែលកើតមាននៅក្នុងភាសាខ្មែរ មានជាអាទិ៍ ការសិក្សាពីអវិជ្ជមានបទនិងអវិជ្ជមានសព្ទដែលមិនអាចកាត់ផ្ដាច់ចេញបានពីប្រភេទពាក្យ វិសាលកម្ម តួនាទី នៃអវិជ្ជមានបទនិងអវិជ្ជមានសព្ទនេះនៅក្នុងយន្តការនៃការស្ថាបនាន័យ (អវិជ្ជមានន័យនិងវិជ្ជមានន័យ)បានឡើយ ហើយការសិក្សានេះទៀតសោត គឺមានលក្ខណៈជាប្រព័ន្ធ។

អន្តរកម្មនិយមជាលក្ខណៈចម្បង ដែលកើតចេញពីការប្រើប្រាស់ភាសា ហើយត្រូវបានប្រើនៅក្នុងចរន្តស្ថាបនិកនិយម។ ឧទាហរណ៍ បើយើងយកពាក្យ *ល្អ* មកវិភាគ យើងមិនទាន់ដឹងថាវាស្ដែងពីវិជ្ជមានន័យឬអវិជ្ជមានន័យនោះទេ ទាល់តែវាចូលរួមក្នុងអន្តរកម្មជាមួយសហបទ ពោលគឺពាក្យទាំងឡាយដែលត្រូវប្រើប្រាស់ជាមួយវាទើបគេអាចយល់ន័យរបស់វាបាន។ ដូចជា *មនុស្ស+ល្អ* > មនុស្សល្អ ជាវិជ្ជមានន័យ, ជើង+ល្អ > **ជើងល្អ** ជាអវិជ្ជមានន័យ, មិន+ល្អ > **មិនល្អ** ជាអវិជ្ជមានន័យ។

សូមបញ្ជាក់ថា តាមទ្រឹស្ដីអន្តរកម្មនិយមដែលមានលក្ខណៈបែបស្ថាបនិកនិយម គេមិនអាចសន្និដ្ឋានថា«*មានន័យដែលកើតមុនឬឋិតនៅក្រៅឯកតាភាសានោះទេ*»។ ន័យ គឺកើតមានព្រមគ្នានឹងពេលគេប្រើប្រាស់ភាសា។ យ៉ាងណាមិញ គេអាចយល់ពីអវិជ្ជមានន័យបានតែតាមរយៈអវិជ្ជមានបទឬអវិជ្ជមានសព្ទដែលជាធាតុចាំបាច់នៃអន្តរកម្ម ហើយអន្តរកម្មនោះឯងដែលជាយន្តការនៃការស្ថាបនាន័យ។ គោលការណ៍ជាសារវន្តនៃការវិភាគក្នុងពេលនេះ គឺផ្អែកលើន័យសត្យានុម័តដែលជាន័យស្ដែងឡើងតាមរយៈភាសា តែមិនមែនជាន័យដែលកើតឡើងតាមរយៈនៃការបកស្រាយឬការយល់ដឹងរបស់បុគ្គលណាម្នាក់នោះទេ។

*អវិជ្ជមានន័យ* គឺជាន័យដែលកើតចេញពីអន្តរកម្មរបស់ឯកតាភាសាដែលអាចជាអវិជ្ជមានបទនិងអវិជុំជមានសព្ទ។ ចំណែកឯ*ន័យបដិសេធ* គឺជាន័យដែលកើតចេញពីប្រតិកម្មពីចេតនារបស់មនុស្សដែលត្រូវបានស្ដែងចេញតាមរយៈឃ្លាឬវាទរូប។ ឧទាហរណ៍*គាត់មិនយល់ ខ្ញុំមិនយល់* ស្ដែងពីអវិជ្ជមានន័យ ហើយអវិជ្ជមាន័យនេះកើតឡើងពីអន្តរកម្មរវាងអវិជ្ជមានបទ*(មិន)* និងសហបទរបស់វា ពោលគឺ*(យល់)* ។ ដូចគ្នាដែរ គេនិយាយថា*ខ្ញុំមិនខ្វីធ្វើយល់ ខ្ញុំមិនព្រមថាយល់ ខ្ញុំមិនធ្វើ ខ្ញុំមិនក្រោក ខ្ញុំមិនឱ្យ* គឺជាឃ្លាដែលមានន័យបដិសេធដែលចេញពីប្រតិកម្មមនុស្ស ពីព្រោះមនុស្សនេះមានចេតនាមិនចង់ធ្វើកិច្ចការដែលគេតម្រូវឱ្យខ្លួនធ្វើ។

អវិជ្ជមានន័យដែលយើងខ្ញុំលើកមកសិក្សានេះមានលក្ខណៈជាសត្យានុម័ត។ ការប្រើប្រាស់អវិជ្ជមានសព្ទ ពេលខ្លះធ្វើឱ្យគូសន្ទនាមានភាពច្របូកច្របល់ក្នុងគំនិត ព្រោះមិនយល់ន័យឬអាចធ្វើរឿងល្អឱ្យក្លាយជាអាក្រក់បានឬអាចធ្វើរឿងអាក្រក់ឱ្យក្លាយជាល្អវិញក៏បានដែរ។

# Abstract

The study on "the negative meaning" is conducted under **Interaction Theory** which has the atomic feacture.

Interaction gains its significant feature from the use of the language and is used in the moviment of construction. Consider, for example, the word ល្អ. the meaning of The word ល្អ is unknown unless it works together with its co-text, i.e. the word(s) that is used with it. yet, its meaning is known when it comes with its co-text. therefore, the phrase មនុស្សល្អ (< មនុស្ស+ ល្អ)has the positive meaning, while សើចល្អ (< សើច+ល្អ)has the negative meaning and មិនល្អ (< មិន+ល្អ)has the negative meaning.

For Interaction, which sticks firmly to the construction, it is nonsense for the contradiction of "the meaning already exists or is out of the linguistric unit." In contrast, for Interaction, the meaning is determined as soon as the language is used. Similarly, the negative meaning is only known through negative words or expressions which are important elements of the interaction, while the interaction is the mechanism of the meaning construction. The essntial principle of the study is based on the exactness indicated by the language and the meaning expressed by a man's demonstration or opinion.

The negative meaning is constructed by the interaction between linguistic units including *negative words* and *negative expressions.* In contrast, *denial meaning* denotes an intentional interaction of the speaker indicated by his speech. ការមិនយល់, *for example, and* ខ្ញុំមិនយល់ indicate the *negative neanning* which is constructed by the interaction betwenen the negative word(មិន) and its co-text (យល់), while ខ្ញុំមិនធ្វើយល់ or ខ្ញុំមិនព្រមថាយល់ or ខ្ញុំមិនធ្វើ or ខ្ញុំមិនញាក or ខ្ញុំមិនឱ្យ are sentences that denote *denial meaning* exspressed by the speaker's interaction because he *intentionally refuses* to do something wanted by others.

The *negative meaning* in this study contains the exactness. The use of *negative expressions* sometimes makes the partner in the convesation compli- cated because of the confusion or can cause a bad situation from a good one or vice versa.

# សង្ខេបនិក្ខេបបទ

ឈរលើមូលដ្ឋាននៃវិចារណកម្មអំពី វិជ្ជមានន័យ អវិជ្ជមានន័យ និងបរិធាតុរបស់វានៅក្នុងសៀវភៅស្ដីអំពី អន្តរកម្មនិយម ដែលមានចំណងជើងថា *ការបង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ* ដែលបោះពុម្ពនៅក្នុងឆ្នាំ២០១០ របស់សាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ ការសិក្សាលម្អិតទៅលើប្រធានបទនិក្ខេបបទ ស្ដីអំពី « អវិជ្ជមានន័យក្នុងភាសាខ្មែរ តាមរយៈអវិជ្ជមានបទនិងអវិជ្ជមានសព្ទ មួយចំនួន (មិន ឥត កុំ គ្មាន អត់ ពុំ ..., ខុស អាក្រក់ ចាំតើ នាងល្អ...) » អាចសម្រេចចេញជារូបរាងនៅក្នុងនិក្ខេបបទនេះ។

តើអ្វីទៅជាអន្តរកម្មនិយម? អន្តរកម្មនិយមគឺជាទ្រឹស្ដីមួយក្នុងការវិភាគភាសាវិទ្យា។ នៅក្នុងក្របខ័ណ្ឌនេះ *«ន័យរបស់ឯកតាភាសាមួយ(ក្នុងន័យទូលាយ)កើតឡើងតាមរយៈអន្តរកម្មរវាងឯកតាភាសានោះជាមួយសហបទរបស់វានៅក្នុងបរិបទមួយកំណត់ច្បាស់លាស់»*។ អន្តរកម្មនិយមជាលក្ខណៈចម្បងដែលកើតចេញអំពីការប្រើប្រាស់ភាសា ហើយ ត្រូវបានប្រើនៅក្នុងចរន្តស្ថាបនិកនិយម។ តាមទ្រឹស្ដីអន្តរកម្មនិយមដែលមានលក្ខណៈបែបស្ថាបនិកនិយម គេមិនអាចសន្និដ្ឋានថា *«មានន័យដែលកើតមុនឬឋិតនៅក្រៅឯកតាភាសានោះទេ»*។ ន័យ គឺកើតមានព្រមគ្នានឹងពេលគេប្រើប្រាស់ភាសា។ យ៉ាងណាមិញ គេអាចយល់ពីអវិជ្ជមានន័យបានតែតាមរយៈអវិជ្ជមានបទឬអវិជ្ជមានសព្ទ ដែលជាធាតុចាំបាច់នៃអន្តរកម្ម ហើយ អន្តរកម្មនោះឯងដែលជាយន្តការនៃការស្ថាបនាន័យ។ ន័យសត្យានុម័តជាន័យស្តែងឡើងតាមរយៈភាសា គឺមិនមែនជាន័យដែលកើតឡើងតាមរយៈនៃការបកស្រាយឬការយល់ដឹងរបស់បុគ្គលណាម្នាក់នោះទេ។

***អវិជ្ជមានន័យ*** ជាន័យដែលកើតចេញពីអន្តរកម្មរបស់ឯកតាភាសាដែលអាចជា អវិជ្ជមានបទនិងអវិជ្ជមានសព្ទ។

អវិជ្ជមានន័យមានលក្ខណៈជាសត្យានុម័ត។ ហេតុនេះ វាមិនប្រែប្រួលទៅតាមបុគ្គលទេ។ ឧទាហរណ៍ យើងអាចនិយាយថា*ជំងឺអេដស៍ជាជំងឺឆ្លងដ៏កាចសាហាវបំផុត គេមិនអាចព្យាបាលវាបានទេ* ។ ទាំងវាទករ ទាំងសហវាទករក៏យល់ថា ជំងឺនេះមិនអាចព្យាបាលជាបានទេ។ ការប្រើប្រាស់អវិជ្ជមានសព្ទ ពេលខ្លះធ្វើឱ្យគូសន្ទនាមានភាពច្របូកច្របល់ក្នុងគំនិត ព្រោះមិនយល់ន័យឬអាចធ្វើរឿងល្អឱ្យក្លាយជាអាក្រក់បានឬអាចធ្វើរឿងអាក្រក់ឱ្យក្លាយជាល្អវិញក៏បានដែរ។

តាមទ្រឹស្ដីអន្តរកម្មនិយម ដើម្បីសិក្សាពីឯកតាភាសា យើងត្រូវស្គាល់ពីគោលវិជ្ជមាននិងគោលអវិជ្ជមានរបស់វាសិន។ តើអ្វីទៅជាគោលវិជ្ជមាននិងគោលអវិជ្ជមានរបស់ឯកតាភាសាមួយ ?

គោលវិជ្ជមាននៃឯកតាភាសាមួយទាក់ទងទៅនឹងសញ្ញាណភាពរបស់ឯកតាភាសានោះ។

ឧទាហរណ៍ *គាត់ឈឺធ្មេញ គាត់បាត់ឈឺធ្មេញហើយ* (បញ្ញត្តិនៃ*ឈឺ* និង*បាត់ឈឺ* ស្តែងឡើងនៅក្នុងគោលវិជ្ជមានដូចគ្នា តែមួយស្តែងពីវិជ្ជមានន័យ រីឯមួយទៀតស្តែងពីអវិជ្ជមានន័យ) តាមរយៈគោលវិជ្ជមាននេះ គេអាចយល់ពីវិជ្ជមានភាពរបស់ឯកតាភាសាមួយ(វិជ្ជមានភាពជាទិដ្ឋភាពនៃគោលវិជ្ជមាន ដែលផ្តល់នូវតម្លៃវិជ្ជមាន)ហើយតម្លៃវិជ្ជមាននេះ អាចសម្រេចឡើងជាវិជ្ជមានន័យឬអវិជ្ជមានន័យដោយអនុលោមទៅតាមសំណង់ន័យដែលត្រូវឆ្លងតាមរយៈអន្តរកម្ម មួយរវាងឯកតាភាសានិងសហបទរបស់វានៅក្នុងបរិបទមួយកំណត់ច្បាស់លាស់។

អាស្រ័យហេតុនេះហើយ ទើបយើងហ៊ានអះអាងថា គ្មានវិជ្ជមានន័យឬអវិជ្ជមានន័យណា ដែលកើតឡើងឯកឯងទេ ហើយក៏គ្មានវិជ្ជមានន័យឬអវិជ្ជមានន័យ ដែលកើតមានមុននិងក្រៅឯកតាភាសាដែលស្តែងពីវាដែរ។

ដូចនេះហើយ យើងមិនអាចសន្និដ្ឋានថា អ្វីជាអវិជ្ជមានន័យឬវិជ្ជមានន័យនៅមុនពេលដែលយើងយល់ដឹងពីដំណើរប្រព្រឹត្តទៅនៃអន្តរកម្មដែលជាចលករនៃការស្ថាបនាន័យនោះឡើយ។ យើងអាចដឹងបាននៅពេលដែលយើងស្គាល់ពីយន្តការនៃការស្ថាបនាន័យ តាមរយៈគោលការណ៍អន្តរកម្មនិយមដែលជាមូលដ្ឋានគ្រឹះនៃការសិក្សា។

នៅក្នុងផ្នែកសម្ព័ន្ធ *មិន* មិនអាចមានអន្តរកម្មជាមួយនាមសព្ទដែលនៅជាប់វាឡើយ។ ផ្ទុយទៅវិញ *មិន* អាចប្រើជាមួយកិរិយាសព្ទដែលស្ថិតនៅជាប់ (ឬមិនជាប់) ខាងស្តាំវាជានិច្ច។ ឆ្លងតាមការសិក្សា យើងអាចនិយាយបានថា អវិជ្ជមានបទ *មិន* ជាទូទៅមិនអាចមានសំណង់ឃ្លាដែលមានរចនាសម្ព័ន្ធទូទៅ (មិន+ន.)ទូលំទូលាយទេ ប៉ុន្តែអវិជ្ជមានបទ *មិន* ថ្វីបើលទ្ធភាពក្នុងសំណេរតាមក្បួនខ្នាតវេយ្យាករមិនអនុញ្ញាតឱ្យមានអន្តរកម្មជាមួយនឹងធាតុជានាមសព្ទក៏ពិតមែន តែចំពោះការនិយាយប្រាស្រ័យទាក់ទងគ្នាជាទូទៅ *មិន* អាចមានលទ្ធភាពទៅរួចក្នុងករណីខ្លះដែលគេប្រើវាជាប្រយោគខ្លីៗ។ ឧទាហរណ៍៖

ក-...*ហ្នឹងមិនមនុស្ស! ម៉េចក៏ឯងថាគ្មានមនុស្សម្នាក់នៅទេ?, ...នុ៎ះមិន យន្តហោះ!*។

ខ- *ឯងថាគ្មានមនុស្សមកមើលល្ខោនទេ យប់នេះ, ឯងមើលន៍ នុ៎ះ! មិនមនុស្ស!*។

តាមរយៈឃ្លានេះ *មិនមនុស្ស* មិនមែនបានសេចក្តីថា វាស្ថិតក្នុងសម្ព័ន្ធឃ្លាតែមួយនោះទេ គឺវាស្ថិតនៅក្នុងប្លង់វាទកម្មពីរផ្សេងគ្នា ប៉ុន្តែនៅក្នុងសម្ព័ន្ធពាក្យក្នុងការនិយាយប្រាស្រ័យទាក់ទងគ្នា ឃ្លាបែបនេះ វាប្រាកដជាមានន័យជាវិជ្ជមានន័យ បញ្ជាក់នូវភាពច្បាស់លាស់ពីរបស់អ្វីមួយ (មនុស្ស)។

ប៉ុន្តែ ចំពោះសំណេរវិញ គេមិនអាចសរសេរ *មិនមនុស្ស *មិនគោ *មិនក្របី ដូចនេះបានឡើយ។ ករណីដូចក្នុងចំណុច*ខ*នេះ ប្រសិនបើជាសំណេរ គេអាច សរសេរដូច ខ១ នេះវិញ៖

ខ១- *ឯងថាគ្មានមនុស្សមកមើលល្ខោនទេយប់នេះ ឥឡូវឯងមើលចុះ! មនុស្សមកមើលយ៉ាងច្រើនកុះករ...*។

ការសិក្សាពីអវិជ្ជមានបទនៅក្នុងសំណង់ឃ្លាដែលមានរចនាសម្ព័ន្ធ មិន+ឈ្នាក់ +កិ. បង្ហាញឱ្យឃើញថា អវិជ្ជមានបទមានអន្តរកម្មមិនត្រឹមតែជាមួយនឹងឈ្នាក់ដែលជាធាតុបិតនៅខាងស្តាំវាប៉ុណ្ណោះទេ តែវាមានទំនាក់ទំនងជាមួយនឹងធាតុដែលនៅជាប់នឹងឈ្នាក់នេះទៀតផង។ សូមមើលឃ្លាខាងក្រោម៖

(២១)« *ប៊ុន-ធឿន មឹងបានជាខុសគំនិតទៅហើយ មឹងមិនបាននឹកស្មានថា សេចក្តីស្នេហាមានកម្លាំងអ៊ីម្ល៉េះ* » (នូ ហាច : *ផ្កាស្រពោន* ជ.ឯ.ម.ទំព័រ១៥៣)។

ឃ្លានេះបង្ហាញពីការសោកភាពរបស់យាយនួន ចំពោះ ប៊ុន ធឿន ដែលបានបញ្ជាក់ថា គាត់មិនធ្លាប់យល់ពីកម្លាំងនៃសេចក្តីស្នេហាដែលមានទំហំធំធេងបែបនេះទេ។

*មិន* នៅក្នុងឃ្លានេះមានអន្តរកម្មជាមួយធាតុដែលជាសហបទស្ថិតនៅខាងស្តាំវា ពោល គឺ*បាន* ។ មានន័យថា ពេល*មិន* មានអន្តរកម្មលើ*បាន* ដែលជា*ឈ្នាក់* ធ្វើឱ្យឃ្លានេះមានន័យផ្សេងពី *មិន* ដែលមានអន្តរកម្មតែទៅលើកិរិយាសព្ទ*នឹកស្មាន* ពោលគឺ ក្នុងឃ្លាដែលគ្មាន*បាន* ។

យើងឃើញថានៅពេលគ្មានឈ្នាក់*ពាន* ដែលជាសហបទរបស់*មិន* នោះ ឃ្លានេះប្រែប្រួលនូវទិដ្ឋភាពន័យ។ ប្រការនេះហើយដែលនាំឱ្យយើងយល់បានថា អវិជ្ជមានបទ*មិន* ជាចលករនៃការស្ថាបនាន័យក្នុងអន្តរកម្មមួយ ដែលវាមិនត្រឹមតែមានទំនាក់ទំនងជាមួយនឹងឈ្នាក់ដែលជាធាតុបិតនៅខាងស្ដាំវាប៉ុណ្ណោះទេ តែវាមានទំនាក់ទំនងជាមួយនឹងធាតុដែលនៅជាប់នឹងឈ្នាក់នេះទៀតផង។

ការប្រើប្រាស់អវិជ្ជមានបទ*មិន* អាចកើតមានទៅបាន ហើយមានភាពត្រឹមត្រូវទាំងទិដ្ឋភាពសម្ព័ន្ធនិងទាំងទិដ្ឋភាពន័យ លុះត្រាតែវាស្ថិតនៅក្នុងសំណង់ឃ្លាដែលមានរចនាសម្ព័ន្ធទូទៅ (មិន+ឈ្នាក់+កិ.) ឬ (មិន+កិ.) ។

ការសិក្សាអំពីអវិជ្ជមានបទ*ឥត* នៅក្នុងនិក្ខេបបទនេះ គឺផ្ដោតទៅលើសំណុំពាក្យដែលមានរចនាសម្ព័ន្ធទូទៅដែលតាងដោយ (ឥត+គុ.កិ.+កិ.+ន.) (ឥត+កិ.) និង(ឥត+គុ.កិ.) ដោយធ្វើការសិក្សាវិភាគទៅលើវិសាលកម្មនៃអវិជ្ជមានបទនេះក្នុងការស្ថាបនាន័យជាមួយនឹងធាតុដែលជាសហបទកន្សោមពាក្យឬវាទកម្មរបស់វា។ ការសិក្សានេះក៏ផ្ដោតផងដែរទៅលើទិដ្ឋភាពនៃអន្តរកម្មនិយម ដោយបានចោទជាសំណួរថា តើក្នុងសំណង់ឃ្លាបែបនេះ *ឥត* មានប្រភេទពាក្យតែមួយគត់ឬយ៉ាងណា? ហើយ ក៏មានចំណោទចោទសួរផងដែរទៅលើតួនាទីឬមុខងាររបស់ពាក្យដទៃទៀតដែលបិតនៅក្នុងបរិបទនៃការប្រើប្រាស់ពាក្យ*ឥត* ដោយហេតុថា នៅក្នុងរចនាសម្ព័ន្ធឃ្លា បើមានធាតុមួយប្រែប្រួលធាតុដទៃទៀតក៏អាចប្រែប្រួលផងដែរ។ ការសិក្សានឹងបង្ហាញឱ្យឃើញដែរថា ការប្រែប្រួលមានលក្ខណៈជាប្រព័ន្ធដែរឬទេ ហើយលក្ខណៈសម្ព័ន្ធមានលក្ខណៈ «រឹងមាំ» ដែលកំណត់ពីន័យរបស់ឃ្លាដែរឬទេ ឬមួយក៏វាគ្រាន់តែជាវេយ្យាករណ៍នៃពាក្យដែលតម្រូវឱ្យមាននិយាមកាសាមួយ មានលក្ខណៈឯកភាពគ្នាក្នុងការប្រើប្រាស់តែន័យសេចក្ដីដែលអាចស្តែងឡើងតាមរយៈតួនាទីរបស់ពាក្យដែលមានឥទ្ធិពល ដោយផ្ទាល់ឬដោយប្រយោលទៅលើសំណង់ឃ្លានិងទៅក្នុងយន្តការនៃការស្ថាបនាន័យ។

ជាមួយនេះ យើងខ្ញុំនឹងលើកយក «សំណុំពាក្យ» មកសិក្សាផងដែរ ដែលពាក្យនេះមានប្រើប្រាស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ថាតើពាក្យ (ណាមួយដែលខ្ញុំបាទចង់លើកយកមកសិក្សា) នេះ អាចនិយាយបានឬមិនបានជាដើម។ ប៉ុន្តែជាទូទៅ សំណុំពាក្យដែលយើងខ្ញុំលើកយកមកសិក្សានេះ គឺពិតជាមានគុណវិបត្តិខាង «ការឯកភាពខាងទិន្នន័យ» ថាតើទិន្នន័យនេះអាចយកជាការបានដែរឬទេ ក្រោយពីការសាកសួរឬស្វែងយល់ពីអ្នកដទៃរួចមក? ពីព្រោះពេលខ្លះ គេអាចទទួលយកបានដែរ តែហាក់ដូចជាមិនតាមធម្មជាតិនោះទេ ដូចជា *«ឥតលុយ»* ធៀបទៅនឹង *«គ្មានលុយ»*។ ម្យ៉ាងទៀត ការសិក្សាពីសំណុំពាក្យនេះមានផលវិបាកមួយ ដោយវាត្រូវបានកាត់ផ្ដាច់ពីបរិបទដែលអាចនាំឱ្យមានការរិះគន់ពីសំណាក់អ្នកសិក្សាផ្នែកភាសាវិទ្យាមួយចំនួន ដែលលោកឱ្យតម្លៃខ្លាំងទៅខាងតួនាទីរបស់បរិបទនោះ។ ម្យ៉ាងវិញទៀត ការសិក្សាពីសំណុំពាក្យនេះគ្មានឯកសារច្បាស់លាស់ ប៉ុន្តែការសិក្សាសំណុំពាក្យអាចមានផលប្រយោជន៍ដល់ការវិភាគស៊ីជម្រៅក្នុងការបកស្រាយដូចតទៅ៖

១- ការសិក្សាពីសំណុំពាក្យនេះនាំឱ្យយើងចៀសផុតពីភាពឆ្លងគ្នានៃធាតុដែលបានប្រើប្រាស់ក្នុងឃ្លានិងពីការបំភាន់នៃបរិបទ។ ការមានពាក្យកាន់តែច្រើន វាពិតជាងាយស្រួលក្នុងការស្ថាបនាន័យមែន ក៏ប៉ុន្តែ វាងាយស្រួលធ្វើឱ្យយើងធ្លាក់ចូលទៅក្នុងភាពភាន់ច្រឡំ ដោយយកគុណតម្លៃនិងអត្ថន័យដែលកើតចេញអំពីពាក្យផ្សេងៗទៀតឬទំនាក់ទំនងនៃពាក្យផ្សេងៗទៀតយកមកធ្វើជាពាក្យរបស់ឃ្លា។

២- ការសិក្សាសំណុំពាក្យនេះនាំឱ្យយើងងាយស្រួលទៅវិញ ប្រសិនបើ វាមានក្របខ័ណ្ឌទ្រឹស្ដីច្បាស់លាស់ យើងខ្ញុំមានគំនិតប្រាកដនិយម ជំហរច្បាស់លាស់ក្នុងការវិភាគនេះ ជាពិសេស វាជាលទ្ធផលនៃការសិក្សាពីពាក្យតាមបែបភាសាវិទ្យា ដែលមានទ្រឹស្ដីអន្តរកម្មនិយមជាប្រទីបបំភ្លឺផ្លូវ។

៣- ការសិក្សាសំណុំពាក្យនាំឱ្យយើងមិនប្រថុយប្រថានទៅនឹងគ្រោះថ្នាក់ជាយថាហេតុ ដែលបណ្ដាលមកពីភាពឆ្លងនៃបរិបទ ហើយអនុញ្ញាតឱ្យសិក្សាទៅលើពាក្យឬជាសំណុំពាក្យណាមួយដោយផ្ទាល់។

ដូចនេះ ការសិក្សារបស់យើង គឺផ្អែកលើសំណុំពាក្យដើម្បីស្វែងយល់ពីសំណុំពាក្យនេះថា តើវាមានអត្ថន័យយ៉ាងណា ហើយវាមានជាប់ទាក់ទងទៅនឹងបរិបទអ្វីខ្លះ? យើងស្វែងយល់ពីតួនាទីរបស់បរិបទ យើងអាចដកបរិបទចេញដើម្បីចូលជ្រៅទៅក្នុងយន្តការនៃការស្ថាបនាន័យតាមរយៈឯកតាភាសា។ ក្នុងន័យនេះ បរិបទគ្រាន់តែជានិយតករនៃន័យ តែមិនមែនជាចលករនៃការស្ថាបនាន័យនោះទេ។

ជាមួយនេះដែរ យើងអាចចោទសួរបានថាតើជាទូទៅគេអាចនិយាយថា*ខ្ញុំឥតលុយ ខ្ញុំអត់លុយ ខ្ញុំគ្មានលុយ* បានដែរឬទេ? ហើយតើ *ឥត* នៅពេលនេះ(ក្នុងសម្ព័ន្ធ) វាអាចដើរតួនាទីជាកិរិយាសព្ទបានដែរឬទេ?

ជាទូទៅ យើងមិនអាចនិយាយថា **ខ្ញុំមិនលុយ* បានទេ ហើយ *?ខ្ញុំឥតលុយ* ក៏គេមិននិយមប្រើដែរ ប៉ុន្តែ គេអាចនិយាយថា *ខ្ញុំអត់លុយ ខ្ញុំគ្មានលុយ* ។ បើយើងពិនិត្យខាងផ្នែកសម្ព័ន្ធ ឃើញថា វាមានលក្ខណៈខុសគ្នារវាង*មិន អត់ ឥត* និង*គ្មាន* ។ ប្រសិនបើយើងសិក្សាវិភាគទៅលើន័យវិញនោះ យើងឃើញថា ធាតុដែលជាអវិជ្ជមានបទទាំងនេះមានលក្ខណៈខុសៗគ្នាក្នុងការស្ថាបនាន័យ។

**ខ្ញុំមិនលុយ* មិនឃើញមានប្រើទេឬបើនិយាយក៏ស្ដាប់មិនបាន។ ហេតុនេះ *មិន* នៅទីនេះ មិនអាចមានតួនាទីជាកិរិយាសព្ទបានឡើយ ពីព្រោះវាគ្មានគុណតម្លៃទាំងឃ្លាទាំងអត្ថន័យ។

*?ខ្ញុំឥតលុយ* ។ ថ្វីត្បិតពេលខ្លះ គេមិនសូវដែលប្រើ*ឥត* ជាមួយនឹងឃ្លាបែបនេះ ប៉ុន្តែវាអាចមានតួនាទីជាកិរិយាសព្ទ ដែលក្នុងបរិបទខ្លះគេអាចយល់ថា*ឥត* ហាក់បីដូចជា*អត់(ខ្ញុំអត់លុយ)*។ តែ*មិន* មិនអាចដូច*អត់* បានទេ ទោះបីនៅក្នុងបរិបទខ្លះ:*ខ្ញុំមិនទៅ ខ្ញុំអត់ទៅ* ហាក់ដូចជំនួសគ្នាបានក៏ដោយ។ តែតាមពិតទៅ*មិន* និង*អត់* មិនដូចគ្នាទេ តើវាខុសគ្នាយ៉ាងដូចម្ដេច? ចំពោះពាក្យ*ឥត* ដូច*អត់* ទាំង*ឥត* ទាំង*អត់* មានមុខងារជាកិរិយាសព្ទស្នូលនៃល្បះបាន តែផ្ទុយទៅវិញ*មិន* មិនអាចជាកិរិយាសព្ទស្នូលនៃល្បះបានទេ។ ក៏ប៉ុន្តែ ទោះបី*មិន* ជាមួយនឹង*អត់* ខុសគ្នានៅក្នុងប្រភេទពាក្យនៅពេលដែល *ឥត* ឬ *អត់* មានមុខងារជាកិរិយាសព្ទដូចនេះក៏ដោយ ក៏យើងអាចសន្និដ្ឋានបានតាមបែបលក្ខណៈសម្ព័ន្ធថា*ឥត* និង *អត់* មានលក្ខណៈខុសពី*មិន* ។

អវិជ្ជមានសព្ទមានសក្ដានុពលក្នុងការស្ថាបនាន័យ ដូចជាអវិជ្ជមានសព្ទ *ខុស* មានអន្តរកម្មជាមួយនឹង *មាត់* បង្កើតបានជាសំណុំពាក្យ*ខុសមាត់* ហើយដែលសំណុំពាក្យបែបនេះ អាចមានន័យច្រើនទៅតាមបរិបទនៃការប្រើប្រាស់។ សំណុំពាក្យឬឃ្លាដែលមានប្រើអវិជ្ជមានសព្ទ ពេលខ្លះមានបង្កប់ទៅដោយន័យ ទាំងវិជ្ជមានទាំងអវិជ្ជមាន ដែលបញ្ហានេះខុសពីទស្សនៈវេយ្យាករណ៍ប្រពៃណីដែលតែងតែប្រកាន់ថា អវិជ្ជមានសព្ទ គឺជាធាតុដែលមានតែអវិជ្ជមានន័យ។ ការប្រើអវិជ្ជមានសព្ទ ក៏ជាមធ្យោបាយមួយសំខាន់ក្នុងការសម្រាល់ន័យ ចំពោះគូសន្ទនា។

២- ការសិក្សាសំណុំពាក្យនេះនាំឱ្យយើងងាយស្រួលទៅវិញ ប្រសិនបើ វាមានក្របខ័ណ្ឌទ្រឹស្តីច្បាស់លាស់ យើងខ្ញុំមានគំនិតប្រាកដនិយម ជំហរច្បាស់លាស់ក្នុងការវិភាគនេះ ជាពិសេស វាជាលទ្ធផលនៃការសិក្សាពីពាក្យតាមបែបភាសាវិទ្យា ដែលមានទ្រឹស្តីអន្តរកម្មនិយមជាប្រទីបបំភ្លឺផ្លូវ។

៣- ការសិក្សាសំណុំពាក្យនាំឱ្យយើងមិនប្រថុយប្រថានទៅនឹងគ្រោះថ្នាក់ជាយថាហេតុ ដែលបណ្តាលមកពីភាពឆ្លងនៃបរិបទ ហើយអនុញ្ញាតឱ្យសិក្សាទៅលើពាក្យឬជាសំណុំពាក្យណាមួយដោយផ្ទាល់។

ដូចនេះ ការសិក្សារបស់យើង គឺផ្អែកលើសំណុំពាក្យដើម្បីស្វែងយល់ពីសំណុំពាក្យនេះថា តើវាមានអត្ថន័យយ៉ាងណា ហើយវាមានជាប់ទាក់ទងទៅនឹងបរិបទអ្វីខ្លះ? យើងស្វែងយល់ពីតួនាទីរបស់បរិបទ យើងអាចដកបរិបទចេញដើម្បីចូលជ្រៅទៅក្នុងយន្តការនៃការស្ថាបនាន័យតាមរយៈឯកតាភាសា។ ក្នុងន័យនេះ បរិបទគ្រាន់តែជានិយតករនៃន័យ តែមិនមែនជាចលករនៃការស្ថាបនាន័យនោះទេ។

ជាមួយនេះដែរ យើងអាចចោទសួរបានថាតើជាទូទៅគេអាចនិយាយថា*ខ្ញុំឥតលុយ ខ្ញុំអត់លុយ ខ្ញុំគ្មានលុយ* បានដែរឬទេ? ហើយតើ *ឥត* នៅពេលនេះ(ក្នុងសម្ព័ន្ធ) វាអាចដើរតួនាទីជាកិរិយាសព្ទបានដែរឬទេ?

ជាទូទៅ យើងមិនអាចនិយាយថា **ខ្ញុំមិនលុយ* បានទេ ហើយ *?ខ្ញុំឥតលុយ* ក៏គេមិននិយមប្រើដែរ ប៉ុន្តែ គេអាចនិយាយថា *ខ្ញុំអត់លុយ ខ្ញុំគ្មានលុយ* ។ បើយើងពិនិត្យខាងផ្នែកសម្ព័ន្ធ ឃើញថាវាមានលក្ខណៈខុសគ្នារវាង*មិន អត់ ឥត* និង*គ្មាន* ។ ប្រសិនបើយើងសិក្សាវិភាគទៅលើន័យវិញនោះ យើងឃើញថា ធាតុដែលជាអវិជ្ជមានបទទាំងនេះមានលក្ខណៈខុសៗគ្នាក្នុងការស្ថាបនាន័យ។

**ខ្ញុំមិនលុយ* មិនឃើញមានប្រើទេឬបើនិយាយក៏ស្តាប់មិនបាន។ ហេតុនេះ *មិន* នៅទីនេះ មិនអាចមានតួនាទីជាកិរិយាសព្ទបានឡើយ ពីព្រោះវាគ្មានគុណតម្លៃទាំងឃ្លាទាំងអត្ថន័យ។

*?ខ្ញុំឥតលុយ* ។ ថ្វីត្បិតពេលខ្លះ គេមិនសូវដែលប្រើ*ឥត* ជាមួយនឹងឃ្លាបែបនេះ ប៉ុន្តែវាអាចមានតួនាទីជាកិរិយាសព្ទ ដែលក្នុងបរិបទខ្លះគេអាចយល់ថា*ឥត* ហាក់បីដូចជា*អត់(ខ្ញុំអត់លុយ)*។ តែ *មិន* មិនអាចដូច*អត់* បានទេ ទោះបីនៅក្នុងបរិបទខ្លះ*ខ្ញុំមិនទៅ ខ្ញុំអត់ទៅ* ហាក់ដូចជំនួសគ្នាបានក៏ដោយ។ តែតាមពិតទៅ*មិន* និង*អត់* មិនដូចគ្នាទេ តើវាខុសគ្នាយ៉ាងដូចម្តេច? ចំពោះពាក្យ*ឥត* ដូច*អត់* ទាំង*ឥត* ទាំង*អត់* មានមុខងារជាកិរិយាសព្ទស្នូលនៃល្បះបាន តែផ្ទុយទៅវិញ*មិន* មិនអាចជាកិរិយាសព្ទស្នូលនៃល្បះបានទេ។ ក៏ប៉ុន្តែ ទោះបី*មិន* ជាមួយនឹង*អត់* ខុសគ្នានៅក្នុងប្រភេទពាក្យនៅពេលដែល *ឥត* ឬ *អត់* មានមុខងារជាកិរិយាសព្ទដូចនេះក៏ដោយ ក៏យើងអាចសន្និដ្ឋានបានតាមបែបលក្ខណៈសម្ព័ន្ធថា*ឥត* និង *អត់* មានលក្ខណៈខុសពី*មិន* ។

